# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ ផ្តោតលើប្រទេសមានសេដ្ឋកិច្ចជឿនលឿនមួយចំនួនក្នុងពិភពលោក និងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួននៅអាស៊ី នៅត្រីមាសទី២ ឆ្នាំ២០១០ ។

## កំណើនសេដ្ឋកិច្ចពិភពលោក

នៅត្រីមាសទី២ ឆ្នាំ២០១០ ផសស ពិត ពីមួយឆ្នាំទៅមួយឆ្នាំ នៅឥណ្ឌូនេស៊ី កើន ៦,២% ដែលជាកំណើនលឿនបំផុតគិតចាប់ពីត្រីមាសទី៣ ឆ្នាំ២០០៨ មក ។ កំណើននេះទទួលបានមួយផ្នែកមកពី កំណើនតម្រូវការខ្លាំងពីប្រទេសចិន ។ កំណើន ផសស នៅ ម៉ាឡេស៊ី ធ្លាក់ចុះមកត្រឹម ៨,៩% ស្របពេលដែល ផសស នៅ សិង្ហបុរី កើនដល់ ១៨,៧% ដែលជាកំណើនលឿនបំផុតលំដាប់ទី២ តាំងពីពេលសិង្ហបុរីចាប់ផ្ដើកំណត់ត្រាកំណើនមក ។ រដ្ឋាភិបាលសិង្ហបុរី បានកែសម្រួលកំណើន ផសស នៅត្រីមាសទី១ ពី ១៦,០% ដល់ ១៧,៤% ។ កំណើន ផសស នៅ ថៃ រួមចុះមកត្រឹម ៩,១% ដោយសារបាតុកម្មប្រឆាំងរដ្ឋាភិបាល ដែលនាំឲ្យមជ្ឈមណ្ឌលពាណិជ្ជកម្មនៅក្រុងបាងកកគាំងសកម្មភាពតាំងពីខែមីនា ដល់ឧសភា ។ ផសស ពីមួយឆ្នាំទៅមួយឆ្នាំ នៅវៀតណាម កើន ៦,៤% ធៀបនឹង ៥,៨% នៅត្រីមាសទី១ ឆ្នាំ២០១០ ។ កំណើននេះ បានពីការរីកលូតលាស់វិស័យកាត់ដេរ សេវាកម្ម កសិកម្ម និង វិនិយោគបរទេសដែលរាប់បញ្ចូលទាំងឧស្សាហកម្មប្រេង និងឧស្ម័ន ផង ។

កំណើន ផសស ពីមួយឆ្នាំទៅមួយឆ្នាំ នៅ ចិន ថយចុះមកត្រឹម ១០,៣% ធៀបនឹង ១១,៩% នៅត្រីមាសទី១ ឆ្នាំ២០១០ ។ ក្នុងអត្រាកំណើននេះ ការរួមចំណែកនៃចំណាយប្រើប្រាស់ មាន ៣,៩ ឯកតាភាគរយ ការបង្កើតមូលធនជាប់លាប់ដុល មាន ៦,៦ ឯកតាភាគរយ និង ការនាំចេញសុទ្ធ មាន ០,៦ ឯកតាភាគរយ ។ កំណើន ផសស ពីមួយឆ្នាំទៅមួយឆ្នាំ ថយចុះមកត្រឹម ៦,៥% នៅ ហុងកុង ៧,១% នៅ កូរ៉េខាងត្បូង និង ១១,៤% នៅ តៃវ៉ាន់ ។ កំណើន ផសស នៅ ជប៉ុន ធ្លាក់ចុះមកត្រឹម ២,៤% ប៉ុន្តែវាកើនដល់ ៣,០% នៅសហរដ្ឋអាមេរិក ដោយសារការរីកលូតលាស់យ៉ាងលឿនក្នុងការនាំចេញ កំណើនការវិនិយោគជាស្តុកទំនិញ និង ភាពប្រសើរឡើងនៃចំណាយប្រើប្រាស់សេវាកម្ម ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់អន្តរជាតិ

នៅត្រីមាសទី២ ឆ្នាំ២០១០ សំពាធបរិត្តផរណានៅតែបន្តកើតមាននៅ ជប៉ុន ស្របពេលដែលប្រទេសជាច្រើនមានកំណើនអតិផរណា ។ នៅ ឥណ្ឌូនេស៊ី អត្រាអតិផរណាកើនដល់ ៤,៤% ធៀបនឹង ៣,៣% កាលពីត្រីមាសទី១ ដោយសារស្បៀងអាហារឡើងថ្លៃក្រោយពេលផុតរដូវច្រូតកាត់ចំបង ។ ម៉ាឡេស៊ី នៅរក្សាបានអត្រាអតិផរណាទាប គឺ ១,៧% រីឯ សិង្ហបុរី មានអត្រាអតិផរណាកើនដល់ ៣,២% ធៀបនឹង ០,៩% នៅត្រីមាសមុន ។ ថ្លៃទំនិញប្រើប្រាស់នៅ ថៃ មានអតិផរណា ២,១% ចំណែកឯនៅ ចិន វាមានកំរិត ២,៧% ។ ថ្លៃទំនិញប្រើប្រាស់ពីមួយឆ្នាំទៅមួយឆ្នាំ នៅ ហុងកុង មានកំណើន ២,១% ធៀបនឹង ១,៩% នៅត្រីមាសមុន ។ កូរ៉េខាងត្បូង មានអត្រាអតិផរណា ២,៦% និង តៃវ៉ាន់ ១,១% ចំណែកឯ ជប៉ុន មានបរិត្តផរណា ០,៩% ។ អតិផរណានៅ តំបន់អឺរ៉ូ គឺ ១,៥% និង សហរដ្ឋអាមេរិក ១,៨% ។

ក្នុងអំឡុងពេលដូចគ្នា ប្រាក់រូពីយ៉ាឥណ្ឌូនេស៊ី ឡើងថ្លៃ ១,៥% ទល់នឹងប្រាក់ដុល្លារអាមេរិក បើធៀបនឹងត្រីមាសមុន ។ ទល់នឹងប្រាក់ដុល្លារអាមេរិក ប្រាក់រីងហ្គីតម៉ាឡេស៊ី ឡើងថ្លៃ ៣,៩% ប្រាក់ដុល្លារសិង្ហបុរី ឡើងថ្លៃ ២,៩% ប្រាក់បាតថៃ ឡើងថ្លៃ ១,៧% ប្រាក់យ៉ុនចិន ឡើងថ្លៃ ០,៩% ដុល្លារតៃវ៉ាន់ ឡើងថ្លៃ ០,១% រីឯ ប្រាក់ដុងវៀតណាម ធ្លាក់ថ្លៃ ០,៩% ។ ជាមួយគ្នានេះដែរ ដុល្លារហុងកុង ធ្លាក់ថ្លៃ ០,៣% ប្រាក់វ៉ុនកូរ៉េខាងត្បូង ធ្លាក់ថ្លៃ ១,៩% ប្រាក់អឺរ៉ូ ធ្លាក់ថ្លៃ ៩,៧% និង ប្រាក់យេនជប៉ុន ធ្លាក់ថ្លៃ ១,៦% ។

## ថ្លៃផលិតផលនៅលើទីផ្សារពិភពលោក

នៅត្រីមាសទី២ ឆ្នាំ២០១០ ពោត និង សណ្តែកសៀង ធ្លាក់ថ្លៃតិចតួច ធៀបនឹងត្រីមាសមុន ។ ពោត US លេខ២ ធ្លាក់ថ្លៃ ៣,៤% មកត្រឹម ១៥៧,៤ដុល្លារ/តោន ។ កៅស៊ូ ប្រភេទ SMR 5 ធ្លាក់ថ្លៃ ០,៧% មកត្រឹម ៣០៨៣,៧ដុល្លារ/តោន អង្ករ (Thai 100%) ធ្លាក់ថ្លៃ ១៨,៥% មកត្រឹម ៤៦១ដុល្លារ/តោន និង សណ្តែកសៀង (US No.1) ធ្លាក់ថ្លៃ ០,៥% មកត្រឹម ៣៧១ដុល្លារ/តោន ។ ប្រេងនៅ ឡើងថ្លៃ ១,៧% ដល់ ៧៧ដុល្លារ/ធុង សាំង ឡើងថ្លៃ ១,០% ដល់ ០,៥៤ដុល្លារ/លីត្រ ហើយ ម៉ាស៊ូត ឡើងថ្លៃ ២,៣% ដល់ ០,៥៥ដុល្លារ/លីត្រ ។

*រៀបរៀងដោយ ស្រ៊ី បុប្ផារ័ត្ន*

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០១០ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា | 7.7 | 13.4 | 10.6 | 10.2 | 6.8 | - | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 5.1 | 5.6 | 5.4 | 6.3 | 6.1 | 4.4 | 3.9 | 4.2 | 5.4 | 5.7 | 6.2 |
| ម៉ាឡេស៊ី | 7 | 5.2 | 5.9 | 6.3 | 4.6 | -6.2 | -3.9 | -1.2 | 4.5 | 16.9* | 8.9 |
| សិង្ហបុរី | 8.5 | 5.7 | 7.7 | 7.7 | 1.1 | -10.1 | -3.5 | 0.8 | 4.0 | 17.4* | 18.7 |
| ថៃ | 6 | 4.5 | 4.8 | 4.9 | 2.6 | -7.1 | -4.9 | -2.8 | 5.8 | 12.0 | 9.1 |
| វៀតណាម | 7.5 | 8.4 | 8.1 | 8.5 | 6.2 | - | - | - | - | 5.8 | 6.4 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន | 9.5 | 9.6 | 10.5 | 11.9 | 9.0 | 6.1 | 7.9 | 9.1* | 10.7 | 11.9* | 10.3 |
| ហុងកុង | 8.3 | 6.5 | 6.6 | 6.4 | 2.4 | -7.8 | -3.8 | -2.2 | 2.6 | 8.0* | 6.5 |
| កូរ៉េខាងត្បូង | 4.7 | 4.7 | 5.0 | 4.9 | 2.2 | -4.4 | -2.2 | 0.4 | 6.1 | 8.1 | 7.1 |
| តៃវ៉ាន់ | 5.7 | 4.1 | 4.6 | 5.2 | 0.1 | -10.2 | -7.5 | -1.3 | 8.4* | 14.6* | 11.4 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ | 1.8 | 1.5 | 2.7 | 2.9 | 0.9 | -2.5 | -4.8 | -4.7 | 0.1 | - | - |
| ជប៉ុន | 3.4 | 2.5 | 2.1 | 2.0 | -0.7 | -9.1 | 0.6 | -4.7 | -1.4 | 4.4* | 2.4 |
| សហរដ្ឋអាមេរិក | 4.4 | 3.7 | 3.3 | 2.2 | 1.1 | -2.6 | -3.9 | -2.5 | 0.1 | 2.4* | 3.0 |

*Sources: International Monetary Fund, Economist and countries' statistic offices. * Updated data*

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០១០ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា | 4.0 | 5.8 | 4.7 | 10.5 | 19.7 | 4.3 | -4.8 | -3.0 | 1.7 | 7.0 | 4.1 |
| ឥណ្ឌូនេស៊ី | 8.3 | 10.5 | 13.4 | 6.4 | 10.1 | 8.5 | 5.6 | 2.78 | 2.6 | 3.6 | 4.4 |
| ម៉ាឡេស៊ី | 1.6 | 3.1 | 3.7 | 2.0 | 5.3 | 3.7 | 1.3 | -2.23 | -0.2 | 1.3 | 1.7 |
| សិង្ហបុរី | 1.7 | 0.5 | 1.0 | 2.1 | 6.5 | 2.1 | -0.5 | -0.4 | -0.3 | 0.9 | 3.2 |
| ថៃ | 2.7 | 4.5 | 4.7 | 2.2 | 5.5 | -0.2 | -2.8 | -2.1 | 1.9 | 3.7 | 2.1 |
| វៀតណាម | 7.8 | 8.2 | 7.7 | 8.3 | 23.3 | 15.1 | 6.2 | 2.6 | 4.6 | 7.5 | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន | 3.9 | 1.8 | 1.5 | 4.8 | 5.9 | -0.6 | 1.5 | -1.26 | 0.7 | 2.1* | 2.7* |
| ហុងកុង | -0.4 | 1.1 | 2.2 | 2.0 | 4.3 | 1.7 | -0.1 | -0.9 | 1.3 | 1.9 | 2.1 |
| កូរ៉េខាងត្បូង | 3.5 | 2.8 | 2.4 | 2.5 | 4.6 | 3.9 | 2.8 | 2.0 | 2.4 | 2.7 | 2.6 |
| តៃវ៉ាន់ | 1.6 | 2.3 | 0.6 | 1.8 | 3.2 | 0.0 | -0.8 | -1.3 | -1.3* | 1.3* | 1.1 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.2 | 2.2 | 2.1 | 2.1 | 3.3 | 1.0 | 0.9 | -0.34 | 0.4 | 1.1 | 1.5 |
| ជប៉ុន | Nil | -0.3 | 0.5 | 0.1 | 1.4 | -0.1 | -1.0 | -2.2 | -2.0 | -1.2 | -0.9 |
| សហរដ្ឋអាមេរិក | 2.7 | 3.4 | 3.2 | 2.9 | 3.8 | -0.2 | -0.9 | -1.6 | 1.4 | 2.3 | 1.8 |

*Sources: International Monetary Fund, Economist and National Institute of Statistics. * Updated data*

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០១០ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា (រៀល) | 4016.30 | 4092.50 | 4103.20 | 4062.70 | 4054.20 | 4108.00 | 4128.60 | 4164.40 | 4163.10 | 4180.11 | 4209.02 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 8938.00 | 9705.00 | 9134.00 | 9419.00 | 9699.00 | 11,630.80 | 10,225.00 | 9887.00 | 9472.44 | 9266.93 | 9,132.00 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.80 | 3.80 | 3.70 | 3.30 | 3.30 | 3.60 | 3.50 | 3.50 | 3.40 | 3.37 | 3.24 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.69 | 1.66 | 1.59 | 1.51 | 4.58 | 1.51 | 1.45 | 1.44 | 1.39 | 1.40 | 1.36 |
| ថៃ (បាត) | 40.20 | 40.20 | 37.90 | 32.22 | 33.36 | 35.29 | 33.98 | 33.96 | 33.30 | 32.90 | 32.33 |
| វៀតណាម (ដុង) | 15,777.00 | 15,859.00 | 15,994.00 | 16,030.00 | 16,382.00 | 16,954.00 | 17,801.00 | 17,841.00 | 18,472.00 | 18,825.67 | 18,993.00 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន (យ៉ន់) | 8.28 | 8.19 | 7.97 | 8.03 | 6.94 | 6.84 | 6.83 | 6.83 | 6.83 | 6.83 | 6.77 |
| ហុងកុង (ដុល្លារហុងកុង) | 7.79 | 7.78 | 7.77 | 7.80 | 7.78 | 7.75 | 7.75 | 7.75 | 7.75 | 7.76 | 7.78 |
| កូរ៉េខាងត្បូង (វ៉ុន) | 1145.00 | 1024.00 | 955.00 | 929.04 | 1137.23 | 1412.50 | 1273.90 | 1239.04 | 1167.77 | 1143.97 | 1166.04 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 33.60 | 32.10 | 32.50 | 32.85 | 31.54 | 34.00 | 33.10 | 32.77 | 32.29 | 31.93 | 31.90 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.80 | 0.80 | 0.80 | 0.70 | 0.84 | 0.76 | 0.71 | 0.70 | 0.68 | 0.72 | 0.79 |
| ជប៉ុន (យ៉េន) | 108.20 | 110.20 | 116.40 | 117.80 | 102.46 | 93.72 | 95.95 | 93.58 | 89.78 | 90.73 | 92.20 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៤-២០១០(មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ពោត (US No. 2) - USA (USD/តោន) | 110.65 | 89.19 | 111.04 | 149.08 | 218.15 | 183.12 | 171.16 | 146.85 | 168.13 | 162.88 | 157.41 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 427.47 | 381.32 | 433.85 | 707.68 | 912.23 | 636.53 | 719.35 | 659.16 | 732.33 | N/A | N/A |
| កៅស៊ូ SMR 5 | 1276.90 | 1430.50 | 1996.30 | 2202.30 | 2586.30 | 1439.77 | 1638.77 | 1924.80 | 2536.03 | 3105.90 | 3083.73 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 221.67 | 262.88 | 282.00 | 305.36 | 615.32 | 522.13 | 499.45 | 307.31 | 569.00 | 565.67 | 461.33 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 262.03 | 224.25 | 213.88 | 294.59 | 460.41 | 434.40 | 420.10 | 411.18 | 390.43 | 372.68 | 370.95 |
| ប្រេងឆៅ - OPEC spot (USD/តោន) | 33.50 | 50.14 | 61.58 | 69.25 | 95.44 | 42.34 | 57.46 | 68.32 | 73.86 | 75.73 | 77.00 |
| សាំង - US Gulf Coast (សេន/លីត្រ) | 30.90 | 42.19 | 47.70 | 53.58 | 62.22 | 31.97 | 43.11 | 46.92 | 49.64 | 53.87 | 54.43 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 29.48 | 44.35 | 51.35 | 55.51 | 76.20 | 34.17 | 40.51 | 46.46 | 51.03 | 53.87 | 55.13 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី២ ឆ្នាំ២០១០ អនុមតិវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ ធ្លាក់ចុះ ៥៧% ។ វិស័យកសិកម្ម ធ្លាក់ចុះ ៧៥% ធៀបនឹងត្រីមាសមុន មកត្រឹម ៤១,៤លានដុល្លារ ហើយវិស័យឧស្សាហកម្ម ធ្លាក់ចុះ ៧៨% មកត្រឹម ៥៤,៥លានដុល្លារ ប៉ុន្តែ វិស័យសេវាកម្ម កើនឡើង ៣៦% ។ នៅត្រីមាសដដែល តម្លៃនៃអនុមតិគម្រោងសាងសង់ កើនឡើងមួយជាបី ដល់ ២០២,១លានដុល្លារ ។ ធៀបនឹងត្រីមាសមុន អនុមតិគម្រោងសាងសង់ភូមិគ្រឹះ និងផ្ទះ កើនឡើង ៤៧% អនុមតិគម្រោងផ្សេងៗ កើនឡើង ៩២% និង អនុមតិគម្រោងសាងសង់ផ្ទះល្វែង កើនឡើង ១០៤៦% ។ ប្រសិនបើគម្រោងទាំងអស់បានអនុវត្តពេញលេញ គេត្រូវការកម្លាំងពលកម្មសរុបប្រមាណ ២៣.៨៤៦នាក់ ។

នៅត្រីមាសទី២ ចំនួនភ្ញៀវមកដល់កម្ពុជាសរុប ធ្លាក់ចុះ ២១% មកត្រឹម ៥៣៧.៤៦៥នាក់ ធៀបនឹងត្រីមាសមុន ។ ភ្ញៀវមកសម្រាកលំហែ ធ្លាក់ចុះ ២២% មកត្រឹម ៤៦៥.៨៣០នាក់ ភ្ញៀវមកធ្វើជំនួញ ធ្លាក់ចុះ ២,០% មកត្រឹម ៣៥.២០៣នាក់ និង ភ្ញៀវមកផ្សេងៗទៀត ធ្លាក់ចុះ ២៤% មកត្រឹម ៣៦.៤៣២នាក់ ។ ក្នុងចំណោមភ្ញៀវមកពីប្រទេសអាស៊ាន ភ្ញៀវវៀតណាម កើនឡើង ៣៣% ធៀបនឹងត្រីមាសមុន ដល់ ១២២.៩៨១នាក់ និងបានកើនឡើងចំនួន ៦ត្រីមាសជាបន្តបន្ទាប់មកហើយ ។ ភ្ញៀវថៃ កើនដល់ ២២.២៧០នាក់ ហើយភ្ញៀវម៉ាឡេស៊ី កើនដល់ ២០.៣៨២នាក់ ។

នៅអំឡុងពេលដដែល ការនាំចេញផលិតផលសំលៀកបំពាក់ កើនឡើង ១៧% ធៀបនឹងត្រីមាសមុន ដល់ ៥០៥,៤លានដុល្លារ ដោយសារការនាំចេញទៅ "ប្រទេសផ្សេងៗ" កើន ២៨% ដល់ ១១២លានដុល្លារ ការនាំចេញទៅប្រទេសជប៉ុន កើន ២៥% ដល់ ៥៤,៨លានដុល្លារ ការនាំចេញទៅអឺរ៉ុប កើន ១៣% ដល់ ១១៥,៩លានដុល្លារ និងការនាំចេញទៅសហរដ្ឋអាមេរិក កើន ១១% ដល់ ៨៥,២លានដុល្លារ ។ ការនាំចេញទៅប្រទេសអាស៊ាន ធ្លាក់ចុះ ១២% មកត្រឹម ៣៧,៥លានដុល្លារ ។ ការនាំចេញផលិតផលកសិកម្មសរុប ធ្លាក់ចុះ ៧៨% ធៀបនឹងត្រីមាសមុន ដោយការនាំចេញកៅស៊ូ ធ្លាក់ចុះ ៦២% ការនាំចេញឈើ ធ្លាក់ចុះ ៧៩% ការនាំចេញត្រី ធ្លាក់ចុះពី ០,៨១លានដុល្លារ ដល់ ០,៥៦លានដុល្លារ ។ ប៉ុន្តែការនាំចេញផលិតផលកសិកម្មផ្សេងៗ នៅនឹងដដែល នៅត្រីមាសទី២ ការនាំចូលសាំង រួមចុះ ២១% មកត្រឹម ១៧,៣លានដុល្លារ ហើយការនាំចូលសម្ភារៈសំណង់ រួមចុះ ៦,៩% មកត្រឹម ១៣,៥លានដុល្លារ ។ ការនាំចូលស៊ីម៉ង់ត៍ ធ្លាក់ចុះ ៤,០% ធៀបនឹងត្រីមាសមុន មកត្រឹម ៥៣,២លានដុល្លារ ហើយការនាំចូលដែកថែប ធ្លាក់ចុះ ៤,៧% មកត្រឹម ៧,២លានដុល្លារ ។ ការនាំចូលក្រណាត់ កើន ៤៩% ដល់ ១៧,៨លានដុល្លារ ប៉ុន្តែការនាំចូលត្រាក់ទ័រ ធ្លាក់ចុះ ១៣% មកត្រឹម ២,៥លានដុល្លារ ។ ការនាំចូលជី ធ្លាក់ចុះ ៣,០% មកត្រឹម ១៣,១លានដុល្លារ ប៉ុន្តែការនាំចូលម៉ាស៊ូត កើន ១០,១% ដល់ ៤៩,៦លានដុល្លារ ហើយការនាំចូលផ្សេងៗ កើន ៦២,៥% ដល់ ៩៤,៤លានដុល្លារ ។

## ហិរញ្ញវត្ថុសាធារណៈ

ចំណូលចរន្ត ធ្លាក់ចុះ ១៣% ធៀបនឹងត្រីមាសមុន ។ ការប្រមូលចំណូលពន្ធ កើនឡើង ៤,៥% ប៉ុន្តែការប្រមូលចំណូលមិនមែនពន្ធ ធ្លាក់ចុះ ៥៧% ។ ចំណូលមូលធន ធ្លាក់ចុះ ១,៩% ប៉ុន្តែចំណាយមូលធន កើនឡើង ១៤២% ធៀបនឹងត្រីមាសមុន ហើយចំណាយចរន្ត កើនឡើង ៤០% ។ ចំណាយលើបៀវត្សរ៍ កើនឡើង ៤៦% ចំណាយលើប្រាក់បំពេញខាត និងប្រាក់ឧបត្ថម្ភខាងសង្គមកិច្ច កើនឡើង ១៩% ប៉ុន្តែចំណាយចរន្តផ្សេងៗ ធ្លាក់ចុះ ១៨% ។ ហិរញ្ញប្បទានបរទេស កើនឡើង ១៧៦% ខណៈដែលហិរញ្ញប្បទានក្នុងស្រុក រួមចុះ ៥៤% ។

## អតិផរណា និងអត្រាប្តូរប្រាក់បរទេស

នៅត្រីមាសទី២ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ពីមួយឆ្នាំទៅមួយឆ្នាំ កើនឡើង ៤,១% ដោយកម្រិតថ្លៃស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា កើនឡើង ៣,៦% ហើយថ្លៃដឹកជញ្ជូន កើនឡើង ៨,៧% ។ នៅត្រីមាសដដែល ប្រាក់រៀល ធ្លាក់ថ្លៃ ០,៧% ទល់នឹងប្រាក់ដុល្លារ និង ២,៣% ទល់នឹងប្រាក់បាតថៃ ប៉ុន្តែឡើងថ្លៃ ០,៩% ទល់នឹងប្រាក់ដុងវៀតណាម ។ មាសឡើងថ្លៃ ៦,៧% ដោយលក់បាន ១៤២,៩ដុល្លារក្នុងមួយជី ។ ម៉ាស៊ូតឡើងថ្លៃ ៦,៥% ដល់ ៣៨៣៥រៀល/លីត្រ ហើយសាំង ឡើងថ្លៃ ៤,៧% ដល់ ៤៣៥៨រៀល/លីត្រ ។

## ការវិវត្តរូបិយវត្ថុ

នៅត្រីមាសទី២ រូបិយវត្ថុទូទៅ (M2) កើនដល់ ១៨.២៦៧ពាន់លានរៀល ធៀបនឹង ១៧.២៣៤ពាន់លានរៀល នៅត្រីមាសមុន ។ ប្រាក់រៀលចរាចរ ធ្លាក់ចុះ ២,៨% មកត្រឹម ២៩៤២ពាន់លានរៀល ហើយបញ្ញើជាប្រាក់រៀល កើន ៤៣% ដល់ ១៧៣ពាន់លានរៀល ។ នៅអំឡុងពេលដដែល បញ្ញើជារូបិយវត្ថុបរទេស កើន ៧,៥% ដល់ ១៤.៧៨៧ពាន់លានរៀល ។ ទ្រព្យសកម្មបរទេសសុទ្ធ កើន ៦,២% ដល់ ១៦.៤៨២ពាន់លានរៀល ដោយសារទ្រព្យសកម្មបរទេស កើន ១,០% ដល់ ១៨.៤៨៧ពាន់លានរៀល ហើយបំណុលបរទេស កើន ៦,០% ដល់ ២០០៦ពាន់លានរៀល ។ ទ្រព្យសកម្មក្នុងស្រុកសុទ្ធ កើន ៣,៨% ដល់ ១៧៨៥ពាន់លានរៀល ។ ឥណទានក្នុងស្រុក កើនដល់ ៩៤៩៩ពាន់លានរៀល ហើយបំណុលផ្សេងៗ កើនដល់ ៧៧១៣ពាន់លានរៀល ។

## ស្ថានភាពភាពក្រីក្រ

នៅខែសីហា ២០១០ អង្កេតរបស់ CDRI បានរកឃើញថា ពលករ ៧ក្រុម ក្នុងចំណោម ១០ក្រុម មានប្រាក់ចំណូលប្រចាំថ្ងៃពិតកើនឡើង ធៀបនឹងខែសីហា ២០០៩ ។ ស្ថានភាពរបស់អ្នកធាក់ស៊ីក្លូ អ្នកលីសែង អ្នកបម្រើភោជនីយដ្ឋាន អ្នកលក់បន្លែតូចតាច អ្នករត់ម៉ូតូឌុប អ្នកស៊ីឈ្នួលធ្វើស្រែ និងកម្មកររោងចក្រកាត់ដេរ បានល្អប្រសើរឡើង ប៉ុន្តែបីក្រុមផ្សេងទៀតមានប្រាក់ចំណូលប្រចាំថ្ងៃពិតធ្លាក់ចុះ ។

ប្រាក់ចំណូលប្រចាំថ្ងៃជាមធ្យមរបស់អ្នកធាក់ស៊ីក្លូ កើន ៨,៥% ធៀបនឹងខែសីហាឆ្នាំមុន ដល់ ៨៣៩៣រៀល ។ អ្នកធាក់ស៊ីក្លូ មាន ៨៧% មកពីតាមបណ្តាខេត្ត ។ ពួកគេភាគច្រើនចំណាយពេល ៦ខែក្នុងមួយឆ្នាំ ប្រកបរបរជាអ្នកធាក់ស៊ីក្លូបន្ទាប់ពីផុតរដូវធ្វើស្រែ ។ ចំណាយជាមធ្យមសម្រាប់ជីវភាពប្រចាំថ្ងៃរបស់អ្នកធាក់ស៊ីក្លូ បានកើន ១៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន ដល់ ៤៨២២រៀល ។ ពួកគេសន្សំប្រាក់បាន ៣០០០រៀលក្នុងមួយថ្ងៃ ដើម្បីឧបត្ថម្ភគ្រួសារ ។

ប្រាក់ចំណូលប្រចាំថ្ងៃពិតជាមធ្យម របស់អ្នកលក់បន្លែតូចតាច កើន ០,៧% ធៀបនឹងឆ្នាំមុន មកដល់ ៨៣៨០រៀល ។ អង្កេតនានា ចាប់ពីខែវិច្ឆិកា ២០០៩ មក បង្ហាញថា ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកលក់បន្លែតូចតាច បានកើនឡើងជាប់រហូត ។ ប៉ុន្តែ អ្នកលក់បន្លែតូចតាច ៦៧% ខ្វះដើមទុនសម្រាប់ដំណើរការលក់ដូរ ដែលនាំឱ្យពួកគេត្រូវធ្លាក់ខ្លួនជំពាក់បំណុល ។

ប្រាក់ចំណូលប្រចាំថ្ងៃពិតជាមធ្យមរបស់អ្នករត់ម៉ូតូឌុបកើន ១០,២% ធៀបនឹងខែសីហាឆ្នាំមុន មកដល់ ១០.៥៤៤រៀល ។ ជាទូទៅ អ្នករត់ម៉ូតូឌុប ចំណាយ ៥០០០រៀលលើចំណីអាហារ និងតែងផ្ញើប្រាក់ទៅឧបត្ថម្ភគ្រួសារ ។ សម្រាប់ប្រាក់សន្សំដែលពួកគេផ្ញើទៅផ្ទះ អ្នករត់ម៉ូតូឌុប ៧០% និយាយថា គឺសម្រាប់តែចំណាយលើចំណីអាហារ ចំណែកឯ ១៩% បានរាយការណ៍ថា សម្រាប់ដំណើរការមុខរបរអាជីវកម្ម ៣% ទៀតប្រាប់ថា សម្រាប់សងបំណុល និង ៨% ទៀតបញ្ជាក់ថា សម្រាប់ចំណាយលើការសិក្សា ។ អ្នករត់ម៉ូតូឌុប ៥២% បានរាយការណ៍ទៀតថា ស្ថានភាពរស់នៅរបស់ខ្លួនប្រែប្រួលប្រសើរឡើង ចាប់តាំងពីបានប្រកបរបរជាអ្នករត់ម៉ូតូឌុប ២៨% ប្រាប់ថា ស្ថានភាពរស់នៅគ្មានប្រែប្រួល ហើយ ២០% បញ្ជាក់ថា ស្ថានភាពរស់នៅរឹតតែលំបាក ។

ប្រាក់ចំណូលប្រចាំថ្ងៃពិតជាមធ្យមរបស់អ្នករើសអេតចាយធ្លាក់ចុះ ៩% ធៀបនឹងខែសីហាឆ្នាំមុន មកត្រឹម ៦៤៧០រៀល ។ អ្នកសម្ភាសន៍ ៩០% បានរាយការណ៍ថា ប្រាក់ចំណូលធ្លាក់ចុះដោយសារចំនួនអ្នករើសអេតចាយកើនឡើង ហើយរបស់អេតចាយធ្លាក់ថ្លៃ ។ អ្នករើសអេតចាយ ៨៧% មិនបានសន្សំប្រាក់ទេ ដោយសាររកចំណូលបានត្រឹមមួយថ្ងៃហូបមួយថ្ងៃប៉ុណ្ណោះ ។ អ្នករើសអេតចាយ ៧៥% រាយការណ៍ថា គ្រួសាររបស់ខ្លួនត្រូវជំពាក់បំណុលគេ ដោយសារខ្វះចំណីអាហារ ឬមានជម្ងឺ ។ អ្នករើសអេតចាយ ៨៨% មកពីតំបន់ជនបទ ហើយ ៦៧% នៃអ្នករើសអេតចាយទាំងអស់ គ្មានដីធ្លីទេ ។

ប្រាក់ចំណូលប្រចាំថ្ងៃពិតជាមធ្យម របស់កម្មករសំណង់មានជំនាញ ធ្លាក់ចុះ ១,៦% ធៀបនឹងខែសីហា ២០០៩ មកត្រឹម ១១.៧២២រៀល ។ កម្មករអ្នកឆ្លើយសម្ភាសន៍ ៦០% រាយការណ៍ថា ប្រាក់ចំណូលធ្លាក់ចុះ ដោយសារកំណើនចំនួនកម្មករសំណង់មានជំនាញ ។ បន្ទាប់ពីបានចំណាយ ៤៣០០រៀលក្នុងមួយថ្ងៃទៅលើចំណីអាហារ កម្មករសំណង់មានជំនាញ អាចសន្សំបាន ១៦៨.០០០រៀលក្នុងមួយខែ សម្រាប់ផ្ញើទៅផ្ទះ ។ អ្នកឆ្លើយសម្ភាសន៍ ៥៧% និយាយថា ជីវភាពគ្រួសាររបស់ខ្លួនប្រែប្រួលប្រសើរឡើង ចាប់តាំងពីបានមកធ្វើការនៅភ្នំពេញ ។

ប្រាក់ចំណូលប្រចាំថ្ងៃពិតជាមធ្យម របស់កម្មកររោងចក្រកាត់ដេរ កើនឡើង ១៤,៣% ធៀបនឹងខែសីហាឆ្នាំមុន ដោយសារជាសំខាន់ ចំនួនម៉ោងធ្វើការបានកើនឡើងពី ៥៣ម៉ោង ដល់ ៦០ម៉ោងក្នុងមួយសប្តាហ៍ ។ ម្យ៉ាងទៀត កម្មកររោងចក្រកាត់ដេរ ៥០% រាយការណ៍ថា ប្រាក់ចំណូលបានកើនឡើង ធៀបនឹងឆ្នាំ២០០៨ និងមាន ១៨% រាយការណ៍ថា ប្រាក់ចំណូលនៅដដែល ហើយ ១៩% ទៀត មិនដឹងច្បាស់ទេ និង ១៣% ទៀត រាយការណ៍ថា ប្រាក់ចំណូលធ្លាក់ចុះ ។ កម្មកររោងចក្រកាត់ដេរ បានកើនចំណាយលើចំណីអាហារ ២៥% ដល់ ៥៨០០រៀលក្នុងមួយថ្ងៃ ប៉ុន្តែនៅសន្សំបានជាមធ្យម ៥២.៦០០រៀលក្នុងមួយខែ សម្រាប់ផ្ញើទៅផ្ទះវិញ ។

*រៀបចំដោយ*

*ស្រ៊ី បុប្ផារ័ត្ន និង*
*ប៊ុន ដូរីណា*

**Cambodia Development Review—2010 Subscription Rates**

**Domestic Subscription (Individual)**

❒ English edition ($14) ❒ Khmer edition (5,000 riels) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❒ English edition ($60 for five copies) ❒ Khmer edition (20,000 riels for five copies) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges). Total payment enclosed..........

**International Subscription (Individual)**

| | | |
|---|---|---|
| ❒ Thailand, Laos, Vietnam | ❒ English edition ($25)* | ❒ Khmer edition ($15)* |
| ❒ Asia and Europe | ❒ English edition ($30)* | ❒ Khmer edition ($20)* |
| ❒ Americas and Africa | ❒ English edition ($35)* | ❒ Khmer edition ($25)* |

* Subscription includes postage. **Payment options:**

**1.** By Telegraphic Transfer – Please add $10 for bank charges to the above Total Cost.
Transfer to:
Account Name: CDRI
Account Number: 133451
Bank Name: ANZ Royal Bank
Bank Address: Phnom Penh, Cambodia
Swift Code: ANZBKHPP
Receiver Correspondent Bank: JP Morgan Chase Manhattan Bank, New York
Swift Code: CHASUS33
CHIP UID 004966

**2.** By Cheque - Please add (overseas) $50 for bank charges to the above Total Cost. Please make Cheque payable to CDRI, attach it to this invoice and send in to Publications.

Title: ❒Mr ❒Ms ❒Dr ❒Other ..........

First name: .......... Last name: .......... Position: ..........

Organisation / Company: ..........

Address (CCC Box if applicable): ..........

City / Province: .......... Country: ..........

Telephone: .......... Fax: ..........

e-mail: .......... ❒ Tick to receive regular information about CDRI publications via e-mail

To subscribe, please fill in this form and return it to CDRI with your payment. Do not send cash through the post.
You will need to inform the Publishing Department at CDRI if your contact details change.

## តារាង១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៣-១០

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | | | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | |
| កសិកម្ម | 3.7 | 12.3 | 26.8 | 498.0 | 135.6 | 92 | 175.3 | 0.0 | 176.1 | 94.4 | 165.7* | 41.4 |
| ឧស្សាហកម្ម | 137.2 | 187.9 | 914.6 | 365.3 | 709.1 | 724.9 | 257.7 | 39.4 | 60.6 | 685.5 | 247.7 | 54.5 |
| *កាត់ដេរ* | *68.1* | *132.6* | *174.4* | *89.4* | *170.7* | *142.8* | *16.4* | *35.0* | *21.9* | *14.2* | *13.1* | *21.3* |
| សេវាកម្ម | 168.4 | 91.8 | 155.5 | 2939.1 | 1742.5 | 10003.2 | 495.6 | 0.0 | 150.2 | 3475.8 | 89.5 | 121.6 |
| *សណ្ឋាគារ និងទេសចរណ៍* | *124.1* | *55.9* | *102.6* | *345.0* | *1048.3* | *8758.1* | *254.1* | *0.0* | *150.2* | *0.0* | *3.78* | *14.0* |
| សរុប | 309.3 | 292.0 | 1096.9 | 3802.4 | 2587.2 | 10570.9 | 928.6 | 39.4 | 386.3 | 4255.7 | 502.9 | 217.5 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | - | - | -41.2 | -95.7 | 882.0 | 1001.7 | -91.2 | -56.8 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | 22.1 | -5.6 | 275.6 | 246.6 | -32.0 | 308.6 | 266.5 | -99.0 | -91.5 | 169.3 | -59.8 | 452.0 |

*Including expansion project approvals. Source: Cambodian Investment Board. *Updated data*

## តារាង២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៣-១០

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | | | លានដុល្លារ | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 20.0 | 30.3 | 45.5 | 33.1 | 79.1 | 154.7 | 32.1 | 6.7 | 2.2 | 9.8 | 5.1 | 7.5 |
| ផ្ទះល្វែង | 91.6 | 167.6 | 204.2 | 213.3 | 297.2 | 221.6 | 95.2 | 18.9 | 6.3 | 28.0 | 11.1 | 127.2 |
| ផ្សេងៗ | 87.3 | 65.6 | 109.1 | 76.8 | 259.6 | 740.9 | 53.7 | 36.7 | 12.2 | 29.0 | 35.2 | 67.4 |
| សរុប | 198.9 | 263.5 | 358.8 | 323.3 | 635.8 | 1117 | 181.1 | 62.3 | 20.7 | 66.8 | 51.4 | 202.1 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | - | - | -48.5 | -65.6 | -66.8 | 222.7 | -23.1 | 293.2 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | -9.5 | 32.5 | 36.2 | -9.9 | 96.7 | 75.7 | 31.9 | -55.8 | -95.7 | -81.0 | -71.6 | 224.4 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង៣. ចំនួនអ្នកដំណើរមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៣-១០

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | | | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | |
| តាមផ្លូវអាកាស | 456.0 | 626.1 | 856.5 | 1029.0 | 1296.5 | 1239.4 | 335.2 | 221.2 | 247.2 | 308.1 | 371.5 | 260.9 |
| តាមផ្លូវគោក និងទឹក | 245.0 | 428.9 | 565.1 | 672.9 | 718.6 | 881.9 | 287.1 | 243.0 | 240.2 | 279.5 | 312.2 | 276.6 |
| សរុប | 701.1 | 1055.0 | 1421.6 | 1701.9 | 2015.1 | 2121.3 | 622.3 | 464.2 | 487.4 | 587.6 | 683.7 | 537.5 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | - | - | 7.7 | -25.4 | 5.0 | 20.6 | 16.4 | -21.4 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | -10.9 | 50.5 | 34.7 | 19.7 | 28.4 | 5.3 | -3.4 | 2.2 | 9.4 | 1.7 | 9.9 | 15.8 |

*Source: Ministry of Tourism*

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៣-១០

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | | | លានដុល្លារ | | | | | |
| ការនាំចេញសរុប | 1787.8 | 2189.4 | 2452.5 | 2920.4 | 3160.1 | 3206.9 | 568.94 | 558.11 | 618.84 | 648.87 | 496.06 | 519.21 |
| ក្នុងនេះ៖ សំលៀកបំពាក់* | 1708.1 | 2108.1 | 2352.8 | 2810.8 | 3050.2 | 3097.8 | 462.2 | 492.4 | 535.5 | 579.3 | 433.3 | 505.4 |
| *- សហរដ្ឋអាមេរិក* | *1101.8* | *1281.7* | *1555.6* | *1851.7* | *1959.9* | *1913.0* | *88.0* | *88.1* | *89.3* | *80.1* | *76.7* | *85.2* |
| *- សហភាពអឺរ៉ុប* | *419.2* | *593.1* | *506.9* | *603.0* | *660.9* | *693.4* | *108.6* | *128.3* | *125.7* | *113.8* | *102.5* | *115.9* |
| *- អាស៊ាន* | *60.8* | *55.4* | *70.7* | *80.4* | *90.3* | *99.6* | *51.0* | *55.1* | *62.1* | *152.1* | *42.7* | *37.5* |
| *- ជប៉ុន* | *18.3* | *23.0* | *25.0* | *40.6* | *30.1* | *26.5* | *110.9* | *112.8* | *149.3* | *128.3* | *124.1* | *154.8* |
| *- ប្រទេសផ្សេងៗ* | *108.0* | *154.9* | *194.6* | *235.1* | *309.0* | *365.3* | *103.7* | *108.1* | *109.1* | *105.0* | *87.3* | *112.0* |
| កសិកម្ម | 79.7 | 81.3 | 99.7 | 109.6 | 109.9 | 109.1 | 106.74 | 65.71 | 83.34 | 69.57 | 62.76 | 13.81 |
| *- កៅស៊ូ* | *35.1* | *38.3* | *36.7* | *41.5* | *41.0* | 35.8 | *11.79* | *8.27* | *15.08* | *16.49* | *11.94* | *13.81* |
| *- ឈើ* | *10.2* | *11.1* | 10.3 | 8.6 | 8.7 | 3.4 | *0.55* | *0.5* | *0.64* | *1.83* | *2.75* | *4.48* |
| *- ត្រី* | *2.8* | *10.6* | 10.1 | 5.9 | 3.2 | 2.3 | *0.83* | *0.85* | *1.11* | *1.2* | *0.81* | *0.56* |
| *- ផ្សេងៗ* | *31.6* | *21.3* | 42.6 | 53.6 | *57.0* | 67.6 | *93.57* | *56.09* | *66.51* | *50.05* | *47.26* | *51.15* |
| ការនាំចូលសរុប* | 1824.9 | 2148.9 | 2513 | 512.2 | 554.8 | 1010.9 | 173 | 177.8 | 148.8 | 133.2 | 139.3 | 174.8 |
| ក្នុងនេះ៖ ផលិតផលសាំង | 33.2 | 30.2 | 40.2 | 38.8 | 58.7 | 70.1 | 16.8 | 15.6 | 19.3 | 19.4 | 22.0 | 17.3 |
| ម៉ាស៊ីន | 109.6 | 109.4 | 93.1 | 113.0 | 122.8 | 113.5 | 34.2 | 40.0 | 46.0 | 43.1 | 44.7 | 49.6 |
| សំភារៈសំណង់ | 80.8 | 95.3 | 134.7 | 56.5 | 69.0 | 77.8 | 13.8 | 14.8 | 15.7 | 13.3 | 14.5 | 13.5 |
| ផ្សេងៗ | 1601.3 | 1914.0 | 2245 | 303.9 | 304.3 | 749.5 | 108.2 | 107.4 | 67.8 | 57.4 | 58.1 | 94.4 |
| ជញ្ជីងពាណិជ្ជកម្ម | -37.1 | 40.5 | -60.5 | 2408.2 | 2605.3 | 2196 | 395.94 | 380.31 | 470.04 | 515.67 | 356.76 | 344.41 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | - | - | -16.0 | 6.5 | 8.8 | 8.2 | -25.2 | 16.6 |
| ការនាំចេញសរុប | - | - | - | - | - | - | -1.7 | -1.9 | 10.9 | 4.9 | -23.6 | 4.7 |
| ការនាំចូលសរុប | - | - | - | - | - | - | -6.5 | 2.8 | -16.3 | -10.5 | 4.6 | 25.5 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 20.1 | 23.4 | 11.6 | 19.5 | 8.5 | 1.6 | -5.4 | -7.0 | -11.4 | 5.3 | -6.3 | 2.6 |
| ការនាំចេញសរុប | 17.5 | 22.5 | 12.0 | 19.1 | 8.2 | 1.5 | 12.1 | -5.5 | -3.0 | 12.1 | -12.8 | -7.0 |
| ការនាំចូលសរុប | 6.9 | 17.8 | 16.9 | -79.6 | 8.3 | 82.2 | 30.9 | -67.5 | 0.0 | -28.0 | -19.5 | -1.7 |

*Import data include tax-exempt imports. Source: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF (web site). Updated data*

តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៣-១០ (ពាន់លានរៀល)

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ចំណូលសរុប | 1764.0 | 2126.0 | 2625.0 | 3259.2 | 1146.1 | 5290.0 | 1101.7 | 1252.7 | 1184.7 | 1346.1 | 1536.8 | 1341.1 |
| ចំណូលចរន្ត | 1733.0 | 2107.0 | 2474.0 | 2881.8 | 1141.6 | 5210.7 | 1097.7 | 1245.7 | 1174.9 | 1337.7 | 1526.4 | 1330.9 |
| ចំណូលពន្ធ | 1220.0 | 1577.0 | 1911.0 | 2270.9 | 965.2 | 4409.9 | 947.4 | 1096.5 | 999.5 | 1224.1 | 1094.1 | 1143.8 |
| ពន្ធក្នុងស្រុក | - | - | - | - | 661.8 | 3248.4 | 712.0 | 838.7 | 731.8 | 808.5 | 820.3 | 890.9 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | - | - | 303.5 | 1161.5 | 235.4 | 257.8 | 268.0 | 303.4 | 273.7 | 253.0 |
| ចំណូលមិនមែនពន្ធ | 513.0 | 530.0 | 563.0 | 610.9 | 176.4 | 800.8 | 150.3 | 149.2 | 176.1 | 225.7 | 432.4 | 187.1 |
| ចំណូលលើទ្រព្យសម្បត្តិ | - | - | - | - | 13.6 | 78.0 | 13.1 | 9.7 | 27.5 | 14.3 | 237.0 | 20.2 |
| លក់ទំនិញ និងសេវា | - | - | - | - | 124.3 | 424.7 | 93.5 | 100.9 | 91.7 | 121.9 | 108.4 | 102.9 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | - | - | - | 38.5 | 298.2 | 43.7 | 38.6 | 56.5 | 89.5 | 84.0 | 61.0 |
| ចំណូលជាមូលធន | 31.0 | 19.0 | 152.0 | 377.4 | 4.5 | 79.3 | 4.0 | 7.0 | 9.8 | 8.4 | 10.4 | 10.2 |
| ចំណាយសរុប | 2757.0 | 2932.0 | 3295.0 | 4174.7 | 1689.7 | 6297.8 | 1650.6 | 1766.1 | 2089.5 | 1877.1 | 2129.4 | 2154.8 |
| ចំណាយជាមូលធន | 1171.0 | 1163.0 | 1328.0 | 1638.1 | 807.4 | 2574.4 | 693.6 | 607.1 | 759.2 | 634.9 | - | 913.0 |
| ចំណាយចរន្ត | 1586.0 | 1769.0 | 1967.0 | 2536.8 | 882.3 | 3809.0 | 752.4 | 1064.7 | 1290.4 | 1332.3 | 831.8 | 1168.1 |
| បៀវត្សរ៍ | 615.0 | 640.0 | 711.0 | 822.0 | 362.6 | 1397.0 | 327.4 | 515.5 | 526.6 | 642.5 | - | 545.6 |
| ឧបត្ថមធន និងជំនួយសង្គមកិច្ច | - | - | - | - | 194.2 | 927.1 | 217.3 | 185.9 | 272.6 | 195.6 | 213.3 | 253.2 |
| ចំណាយចរន្តផ្សេងទៀត | - | - | - | - | 325.5 | 1384.9 | 207.7 | 363.2 | 491.2 | 494.3 | 449.6 | 369.3 |
| សមតុល្យជាទូទៅ | -993.0 | -806.0 | -706.0 | -915.6 | -543.6 | -1007.8 | -548.9 | -513.4 | -904.8 | 90.2 | -592.6 | -813.7 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 886.0 | 864.0 | 1127.0 | 1360.7 | 741.5 | 2055.1 | 507.8 | 326.7 | 484.5 | -531.0 | 270.8 | 746.0 |
| ហិរញ្ញប្បទានក្នុងស្រុក | 106.0 | 148.0 | -396.0 | -445.1 | -185.8 | -127 | -310.3 | 236.5 | 316.4 | 406.4 | 422.8 | 194.1 |

*Source: MEF web site*

តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៣-១០

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | | | | 2009 | | 2010 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| (ខែតុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | 1.1 | 3.9 | 5.8 | 4.7 | 5.8 | 19.7 | 4.3 | -4.8 | -3.0 | 1.7 | 7.0 | 4.1 |
| - ម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 1.5 | 6.4 | 8.6 | 6.4 | 9.9 | 33.1 | 6.1 | -5.2 | -2.7 | 1.8 | 7.8 | 3.6 |
| - ដឹកជញ្ជូន | 4.9 | 9.7 | 11.4 | 9.1 | 5.8 | 19.4 | -13.0 | -16.5 | -13.8 | 2.4 | 12.9 | 8.7 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 3973.3 | 4016.3 | 4119.7 | 4119.0 | 4062.7 | 4058.2 | 4111.6 | 4128.6 | 4164.4 | 4157.3 | 4180.1 | 4209.0 |
| រៀលក្នុង ១ បាតថៃ | 95.8 | 99.9 | 102.6 | 108.7 | 122.8 | 123.5 | 116.6 | 119.2 | 122.9 | 126.0 | 127.0 | 129.9 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.6 | 25.5 | 25.8 | 25.1 | 25.0 | 24.8 | 23.6 | 23.3 | 23.5 | 23.0 | 22.3 | 22.1 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 41.4 | 46.3 | 54.0 | 70.6 | 83.2 | 105.9 | 105.6 | 110.7 | 123.2 | 133.8 | 133.9 | 142.9 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 1508.0 | 2088.0 | 2633.0 | 3140.0 | 3262.3 | 4555.2 | 2873.7 | 3056.9 | 3867.0 | 3381.9 | 3599.5 | 3835.1 |
| ថ្លៃសាំង (រៀល/លីត្រ) | 2150.0 | 2833.0 | 3442.0 | 4004.0 | 4005.0 | 4750.8 | 3112.6 | 3452.4 | 3371.1 | 3940.2 | 4163.0 | 4358.7 |

*Sources: NIS, NBC and CDRI*

តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៣-១០ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 4027.0 | 4,797.0 | 5,475.0 | 7,224.0 | 10,735.0 | 10,345.0 | 11,222.0 | 12,611.0 | 13,869.0 | 14,655.0 | 15,514.6.0 | 12,610.9 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -698.0 | -467.0 | -450.0 | -282.0 | 576.0 | 1513.3 | 1,266.0 | 1,249.0 | 1,042.0 | 1,573.0 | 1,720.0 | 1,785.3 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -128.0 | -209.0 | -421.0 | -953.0 | -1816.0 | -2987.0 | -3048.0 | -2889.0 | -2463.0 | -2252.0 | -2484.8 | -2362.7 |
| ឥណទានដល់ផ្នែកឯកជន | 1337.0 | 1817.0 | 2394.0 | 3630.0 | 6386.0 | 9894.0 | 9814.0 | 10,129.0 | 10,127.0 | 10,532.0 | 11,146.7 | 11,859.1 |
| រូបិយវត្ថុទូទៅ M2 | 3329.0 | 4330.0 | 5025.0 | 6942.0 | 11,311.0 | 11,858.0 | 12,488.0 | 13,859.0 | 14,912.0 | 16,228.0 | 17,234.5 | 18,267.1 |
| រូបិយវត្ថុ M1 | 937.0 | 1153.0 | 1323.0 | 1658.0 | 2052.0 | 2399.0 | 2545.0 | 2695.0 | 2773.0 | 3120.0 | 3148.5 | 3115.1 |
| រូបិយវត្ថុផ្សេងៗ | 2392.0 | 3177.0 | 3702.0 | 5285.0 | 9259.0 | 9459.0 | 9942.0 | 11,164.0 | 12,139.0 | 13,108.0 | 14,086.0 | 15,152.0 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 15.2 | 30.0 | 16.1 | 38.1 | 62.9 | 4.8 | 3.7 | 9.1 | 18.7 | 36.9 | 38.0 | 6.0 |
| រូបិយវត្ថុ M1 | 15.3 | 23.0 | 14.7 | 25.3 | 23.8 | 16.9 | 6.5 | 9.2 | 18.7 | 30.1 | 23.7 | -1.1 |
| រូបិយវត្ថុផ្សេងៗ | 15.2 | 32.8 | 16.6 | 42.8 | 75.2 | 2.2 | 2.9 | 9.1 | 18.7 | 38.6 | 41.7 | 7.6 |

*Source: National Bank of Cambodia*

តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2007 | 2007 | 2008 | 2009 | | | 2010 | | | 2010 | | |
| | | វិច្ឆិកា | វិច្ឆិកា | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | កុម្ភៈ | ឧសភា | សីហា |
| អ្នកធាក់ស៊ីក្លូ | 8075 | 9675 | 12628 | 8896 | 7738 | 7446 | 9413 | 9570 | 8393 | 10.3 | 7.6 | 8.5 |
| អ្នកលីសែង | 8588 | 9119 | 9005 | 10,319 | 8159 | 9566 | 9953 | 9340 | 10,500 | -5.0 | -9.5 | 28.7 |
| អ្នកលក់បន្លែតូចតាច | 8220 | 8552 | 9926 | 9764 | 8323 | 7647 | 7826 | 8062 | 8380 | 2.8 | -17.5 | 0.7 |
| អ្នករើសអេតចាយ | 5422 | 5727 | 4652 | 6637 | 7087 | 4693 | 6238 | 7407 | 6452 | 21.7 | 11.6 | -9.0 |
| អ្នកបំរើតុភោជនីយដ្ឋាន* | 4482 | 4643 | 4327 | 4346 | 4574 | 5568 | 5131 | 5380 | 6418 | 19.8 | 23.8 | 40.3 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 5516 | 6426 | 8697 | 7126 | 5785 | 5003 | 5358 | 6260 | 6177 | -23.9 | -12.2 | 6.8 |
| កម្មកររោងចក្រកាត់ដេរ | 7568 | 7240 | 6554 | 6691 | 7410 | 7745 | 7557 | 7491 | 8470 | 11.9 | 12.0 | 14.3 |
| អ្នករត់ម៉ូតូឌុប | 10,634 | 11,872 | 15,691 | 12,148 | 9569 | 9696 | 11,302 | 10,274 | 10,544 | -3.0 | -15.9 | 10.2 |
| កម្មករសំណង់គ្មានជំនាញ | 6155 | 7777 | 8779 | 9956 | 9444 | 8132 | 7699 | 9013 | 11,722 | 25.9 | -9.5 | -1.6 |
| កម្មករសំណង់មានជំនាញ | 11,154 | 11,286 | 12,710 | 13,688 | 11,918 | 13,011 | 11,924 | 11,928 | 8733 | 1.3 | -12.9 | -7.5 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice -field workers, garment workers, unskilled workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI*